អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៤ ខែមិថុនា ឆ្នាំ ២០១៥

# សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត

នៅថ្ងៃទី២ ខែ មិថុនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានដាក់ចេញនូវសេចក្តីសម្រេចលើកលែងការចោទប្រកាន់ប្រឆាំងនឹង ស៊ូ ម៉េត ដែលជាជនសង្ស័យម្នាក់ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ ចេញដោយសហព្រះរាជអាជ្ញាស្តីទីអន្តរជាតិ កាលថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ២០០៩។

សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា មរណភាពរបស់ ស៊ូ ម៉េត បានបញ្ចប់ការចោទប្រកាន់បទព្រហ្មទណ្ឌប្រឆាំងនឹងរូបគាត់។ ការកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើស ដែលត្រូវបានចោទប្រកាន់ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នឹងត្រូវធ្វើឡើងនៅក្នុងពេលចេញដីកាដំណោះស្រាយ អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង។

អនុលោមតាមវិធាន ៥៦(២)នៃវិធានផ្ទៃក្នុង ដើម្បីឲ្យសាធារណជន ទទួលបានព័ត៌មានគ្រប់គ្រាន់អំពីការវិវឌ្ឍនៃដំណើរការនីតិវិធី ខណៈដែលថែររក្សាបានផងដែរនូវភាពសម្ងាត់នៃសំណុំរឿង សហចៅក្រមស៊ើបអង្កេតបានសម្រេចដាក់ជាសាធារណៈនៃសេចក្តីសម្រេចនេះ ដោយមានការកោសលុបចេញនៅផ្នែកខ្លះ។

សេចក្តីសម្រេចនេះត្រូវបានធ្វើចំណាត់ថ្នាក់ជាឯកសារសាធារណៈ និងអាចរកបាននៅលើគេហទំព័រអ.វ.ត.ក www.eccc.gov.kh/document/court/2-June-2015-Sou-Met

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
ទូរស័ព្ទអចល័ត: ៨៥៥ (0) ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទអចល័ត: ៨៥៥ (0) ៨៦១ ៦៦៩
សារអេឡិកត្រូនិក: olsenl@un.org